# បទឧទ្ទេសនាម
## របស់
## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ដើម្បីពិភាក្សា និង អនុម័ត សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣

*រដ្ឋសភា, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០២២*

ខ្ញុំបាទសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ជូនចំពោះ ៖

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាម ឃឿន** ប្រធានស្តីទី នៃរដ្ឋសភា;
- លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី ២ នៃរដ្ឋសភា;
- សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ខាម ឃឿន ប្រធានស្តីទី នៃរដ្ឋសភា**, គណៈអចិន្ត្រៃយ៍ នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម, ព្រមទាំងគណៈកម្មការ ពាក់ព័ន្ធទាំងអស់ នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ ដើម្បីពិនិត្យ និង អនុម័ត ដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣** ចូលក្នុងរបៀបវារៈ នៃសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបាន រៀបចំសេចក្តីថ្លែងហេតុពិស្តារមួយគោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភារួចហើយ, ហើយ **ឯកឧត្តម ឈាង វុន** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភា ក៏បានរាយការណ៍ បន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម, និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង; ដូច្នេះ, នៅពេលនេះ, ខ្ញុំបាទសូមអនុញ្ញាត ធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទគោរពសុំ ការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬក៏

សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមរបស់ខ្លួន រួមទាំងការបញ្ជាក់តួលេខ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តម ឈាង វុន** បានរាយការណ៍ជូនអង្គរដ្ឋសភា មុននេះ ។

## I. អំពីរចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំស្របតាមការកំណត់ដោយបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ, ពិសេស ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ទាំងខាងទម្រង់, ខ្លឹមសារ និង កាលវសាន្ត, ដូចដែលឯកឧត្តមប្រធានគណៈកម្មការទី ២ បានគូសបញ្ជាក់ពីខាងដើមរួចហើយ ។ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ នេះ ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២២ ។

## II. អំពីបរិការណ៍ផ្នែកម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣, ដែលជាឆ្នាំចុងក្រោយនៃអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា, ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាកំពុងងើបឡើងវិញ និង ត្រឡប់ទៅរកភាពប្រក្រតី បន្ទាប់ពីរាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ឈ្លាសវៃ និង ម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, ទទួលបានជោគជ័យដ៏ត្រចះត្រចង់ ក្នុងការប្រយុទ្ធនឹងការរីករាលនៃជំងឺកូវីដ-១៩ និង ក្នុងការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺនេះ បានយ៉ាងល្អ, ទាំងការការពារសុខភាពសាធារណៈ, ការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច, និង ការធានាទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, ដែលអនុញ្ញាតឱ្យកម្ពុជាបើកប្រទេសឡើងវិញ ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០២១ និង បានធ្វើឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ចក្នុងស្រុក ចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ ។ ទោះជាយ៉ាងនេះក្តី, វិបត្តិនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាន នាពេលកន្លងមកនោះទេ, ក៏ប៉ុន្តែ ក៏បានបង្កើតនូវវិបាកអវិជ្ជមានជាច្រើនលើជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ក៏ដូចជា បង្កើតបញ្ហាជារចនាសម្ព័ន្ធមួយចំនួនក្នុងរយៈពេលមធ្យម ដែលអាចប៉ះទង្គិចដល់គន្លងអភិវឌ្ឍន៍របស់កម្ពុជាក្នុងរយៈពេលវែង ។

ជាមួយគ្នានេះ, កម្ពុជា, ក៏ដូចជាប្រទេសនានា ក្នុងតំបន់ និង ពិភពលោក, បាន និង កំពុងទទួលរងនូវផលប៉ះពាល់ពីវិបត្តិថ្មីមួយទៀត គឺ សង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន ដែលវិបត្តិនេះបានរុញអត្រាអតិផរណា ឱ្យកើនឡើងកាន់តែខ្ពស់, ជាពិសេស ការឡើងថ្លៃប្រេងឥន្ធនៈ, ចំណីអាហារ, ជីកសិកម្ម, និង ទំនិញជាច្រើនប្រភេទទៀត ។ ឆ្លៀតឱកាសនេះ, ខ្ញុំសូមគូសបញ្ជាក់ជូនថា ក្នុងការដោះស្រាយបញ្ហាសម្ពាធអតិផរណានេះ, បន្ថែមពីលើកម្មវិធីជំនួយសង្គម តាមរយៈ

ការឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ និង ងាយរងគ្រោះ, រាជរដ្ឋាភិបាលក៏បានសម្រេចជាលើកដំបូង ដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ ២០២២ នេះ នូវ "កម្មវិធីឧបត្ថម្ភសាច់ប្រាក់មួយគ្រាជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងមានសម្ពាធអតិផរណា" ដែលជាកម្មវិធីជំនួយសង្គមពិសេសមួយ ផ្តល់ជូនគ្រួសារប្រជាពលរដ្ឋងាយរងហានិភ័យនៅទូទាំងប្រទេស ។

អាស្រ័យដោយអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុអំពីសេចក្តីព្រាងច្បាប់នេះ បានគូស-វាសលេចលម្អិតរួចហើយ អំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣ ព្រមទាំងអំពីវិធានការគោលនយោបាយមុតស្រួចមួយចំនួន ដែលត្រូវបានដាក់ចេញ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ប្រកបដោយចីរភាព និង បរិយាប័ន្ន, ដូចនេះ, ខ្ញុំបាទសូមជម្រាបជូនជាសង្ខេបថា តាមការវាយតម្លៃពាក់កណ្តាលឆ្នាំកន្លងមក, សេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ២០២២ ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើនក្នុងអត្រា ៥,៤%, ទោះបីជាទទួលរងផលប៉ះពាល់ពីវិបត្តិសង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន យ៉ាងណាក្តី, ដោយសារការបន្តនូវភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក បានវិលត្រឡប់មករកប្រក្រតីភាពវិញ ។ ដោយឡែក, សម្រាប់ឆ្នាំ ២០២៣, សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ **៦,៦%** ហើយ ផសស សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថា នឹងកើនឡើងដល់ **១ ៩២៤** ដុល្លារអាម៉េរិក ធៀបនឹង **១ ៧៨៥** ដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ ។ ទោះជាយ៉ាងនេះក្តី, ការព្យាករកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២២ និង ឆ្នាំ ២០២៣ នេះ ក៏នៅត្រូវបានព័ទ្ធដោយភាពមិនប្រាកដប្រជាខ្ពស់, ជាពិសេសបញ្ហាប្រឈម និង/ឬ ហានិភ័យ ដែលបង្កឡើងដោយភាពមិនអំណោយផលនៃកត្តាមួយចំនួនរួមមាន៖ ការអូសបន្លាយសង្គ្រាមនៅអ៊ុយក្រែន, បញ្ហាកោះតៃវ៉ាន់, ការកើនឡើងនូវអតិផរណា, ការដំឡើងអត្រាការប្រាក់នៃធនាគារកណ្តាលសហរដ្ឋអាម៉េរិក, ការរឹតបន្តឹងកាន់តែលឿន និង ខ្លាំងជាងមុន នូវគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍, ការថមថយនៃសេដ្ឋកិច្ចចិន និង សេដ្ឋកិច្ចតំបន់សហភាពអឺរ៉ុប ដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ការនាំចេញរបស់កម្ពុជា ។ ការណ៍នេះ, ជាយថាហេតុ, នឹងធ្វើឱ្យកំណើនជារួម អាចនឹងសម្រេចបានទាបជាងការរំពឹងទុកនៅឆ្នាំ ២០២២ និង ឆ្នាំ ២០២៣ ។

បញ្ហាប្រឈមដ៏ស្រួចស្រាល់ដូចជម្រាបជូនខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលផ្តល់អាទិភាពជាចម្បងលើ "**មនុស្ស**" សម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៣ ដោយត្រូវគិតគូរដល់សុខភាព, ការគាំទ្រជីវភាពរស់នៅ និង ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ, ទន្ទឹមនឹងការប្រឹងប្រែងទ្រទ្រង់ការងើបឡើងវិញនៃសេដ្ឋកិច្ច ។ លើសពីនេះ, ការគិតគូរអំពីគ្រប់ទិដ្ឋភាពនៃការបោះឆ្នោត

ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៧ ឆ្នាំ ២០២៣ និង ការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍-លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២ ក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការធ្វើផែនការថវិកាឆ្នាំ ២០២៣ នេះ យ៉ាងល្អិតល្អន់ និង ម៉ត់ចត់ផងដែរ ។

## III. អំពីគោលចំណងគោលនយោបាយនៃការរៀបចំថវិកាឆ្នាំ ២០២៣

ក្នុងគោលដៅខាងលើនេះ, ថវិកាឆ្នាំ ២០២៣ ត្រូវបានរៀបចំដោយបង្វែរធនធានឆ្ពោះទៅបន្តរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជាលំនឹងនៃសង្គម និង ដោយតម្រង់ការវិភាជថវិកាសម្រាប់ការអនុវត្តសកម្មភាពអាទិភាព ដែលត្រូវបានកំណត់ក្នុងកម្មវិធី និង អាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមានជាអាទិ៍៖

១- ការបន្តគ្រប់គ្រងឱ្យបាននូវការរីករាលដាលនៃជំងឺកូវីដ-១៩ និង ការបន្តអន្តរាគមន៍ក្នុងការគ្រប់គ្រងផលប៉ះពាល់ដែលបណ្តាលមកពីជំងឺនេះ ។

២- ការបន្តកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និង ប្រព័ន្ធសុខាភិបាលប្រកបដោយគុណភាព និង មានភាពឆ្លើយតបខ្ពស់ ។

៣- ការបន្តលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ក៏ដូចជាការកែលម្អប្រព័ន្ធ-អប់រំឱ្យកាន់តែមានគុណភាពខ្ពស់ ។

៤- ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ។

៥- ការផ្តល់អាទិភាពពិសេសលើការដំឡើងបៀវត្សជូនមន្ត្រីរាជការគ្រប់ប្រភេទ បន្ទាប់ពីការអាក់ខានអស់រយៈពេលពីរឆ្នាំ (ឆ្នាំ ២០២១-២០២២) ដើម្បីខិតឱ្យទៅកៀកនឹងគោល-នយោបាយបៀវត្សអប្បបរមា ដែលរាជរដ្ឋាភិបាលបានកំណត់កាលពីដើមអាណត្តិនៃនីតិកាល-ទី ៦ នេះ ។

៦- ការដំឡើងរបបសោធនជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ព្រមជាមួយនឹងការកាត់បន្ថយគម្លាតប្រាក់សោធន រវាងអ្នកចូលនិវត្តចាស់ និង ថ្មី ។

៧- ការបន្តស្តារ និង ជំរុញកំណើនសេដ្ឋកិច្ច ឱ្យស្ទុះងើបឡើងវិញ ដើម្បីបន្តបង្កើតការងារជូនប្រជាជន, ជាពិសេសស្រទាប់យុវជន, និង ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញផង និង ជំរុញបង្កើនចំណូលថវិកាជាតិផង ។

៨- ការបន្តអភិវឌ្ឍធនធានមនុស្ស ។

៩- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត, ឌីជីថល, និង បៃតង ។

១០- ការបន្តអភិវឌ្ឍ និង ការបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម ។

១១- ការជំរុញពិពិធកម្មសេដ្ឋកិច្ច និង ការលើកកម្ពស់ភាពប្រកួតប្រជែង ។ និង

១២- ការធានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៧ ក៏ដូចជាការទ្រទ្រង់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និង ការធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២ ។

## IV. អំពីក្របខ័ណ្ឌថវិកាឆ្នាំ ២០២៣

ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៣ ត្រូវបានកំណត់ដូចតទៅ ៖

១-ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ចំណូលក្នុងប្រទេសថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **២៩,៣ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៧,២ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **២២,៣៣% នៃ ផសស, មានកំណើន ១៤,៥%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ។ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៣ មានគោលដៅបង្កើន **ចំណូលចរន្តថវិការដ្ឋ** ឱ្យបានស្មើនឹង **២១,៤៦% នៃ ផសស** ដែលមានកំណើនចំនួន **១,២៧ ពិន្ទុភាគរយនៃ ផសស** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ពោលគឺ នឹងសម្រេចបានខ្ពស់ជាង **គោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ** ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម **០,៣ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ ២០១៩-២០២៣ ។

២-ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **៣៩,២ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៩,៦ ប៊ីលានដុល្លារអាម៉េរិក**, ស្មើនឹង **២៩,៨៧% នៃ ផសស, មានកំណើន ១៣%** ធៀបនឹងច្បាប់ឆ្នាំ ២០២២; ក្នុងនោះ **ចំណាយចរន្តថវិការដ្ឋ** ត្រូវបានគ្រោងចំនួន **២២,៩ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៥,៦ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **១៧,៤៧% នៃ ផសស, កើនឡើង ១០%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ។

៣-តុល្យភាពរួមនៃថវិកាឆ្នាំ ២០២៣

នៅក្នុងក្របខ័ណ្ឌ **ថវិការដ្ឋ ឬ ថវិកាជាតិ**, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាលអាចរក្សា **អតិរេកថវិកាចរន្ត** ឱ្យបានក្នុងកម្រិតប្រមាណ **៣,៩៩% នៃ ផសស** នៅឆ្នាំ ២០២៣, ធៀបនឹងច្បាប់ឆ្នាំ ២០២២ ដែលមានចំនួន **២,៨៦% នៃ ផសស** ។ ជាលទ្ធផល, **ឱនភាពថវិកាជាតិសរុប** នឹងមានទំហំស្មើនឹង **-៧,៥៤% នៃ ផសស** គឺថយចុះពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០២២ ដែលស្មើនឹង **-៧,៥៨% នៃ ផសស** ។ ឱនភាពនេះត្រូវបានបំពេញតុល្យភាពដោយ៖ (១). **ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ **៤,៧០% នៃ ផសស**; (២). **មូលនិធិទ្រទ្រង់ថវិកា** ក្នុងទំហំ **០,៩៨% នៃ ផសស**; (៣). **ប្រាក់បញ្ញើរាជរដ្ឋាភិបាល** ក្នុងទំហំ **១,៨៦% នៃ ផសស**, ស្មើនឹង **២ ៤៣៩ ប៊ីលានរៀល** ឬ សមមូលនឹង **៦០០ លាន**

**ដុល្លារអាមេរិក**, និង **ការបោះផ្សាយលក់មូលបត្ររដ្ឋ** ចំនួន **៨១៣ ប៊ីលានរៀល** ឬ សមមូលនឹងប្រមាណ **២០០ លានដុល្លារអាមេរិក** ដើម្បីបំពេញតម្រូវការចំណាយ, ទាំងចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈ, ជាពិសេសសម្រាប់ការបន្តអនុវត្តកម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងបរិការណ៍នៃការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី និង **ការត្រៀមដោះស្រាយថវិកា (ប្រមាណ ១០០ លានដុល្លារអាមេរិក) សម្រាប់អគ្គិសនីកម្ពុជា ដើម្បីធានាស្ថិរភាពថ្លៃអគ្គិសនី កុំឱ្យកើនលើសកម្រិតថ្លៃកំពុងអនុវត្តបច្ចុប្បន្ន ជូនប្រជាពលរដ្ឋប្រើប្រាស់** ។

## V. អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២៣ មានគោលដៅបង្កើន **ចំណូលក្នុងប្រទេសថ្នាក់ជាតិ** ឱ្យមានទំហំស្មើនឹង **២៦,៧ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៦,៦ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **២០,៣៥% នៃ ផសស**, គឺមានកំណើន **១៣,៨%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ។ ក្នុងក្របខ័ណ្ឌនេះ, ខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ បានរៀបរាប់រួចហើយអំពីគោលដៅ **ចំណូលចរន្ត**, ទាំងគោលដៅ **ចំណូលសារពើពន្ធ** និង **ចំណូលមិនមែនសារពើពន្ធ**, ព្រមទាំងអំពីគោលដៅ **ចំណូលមូលធន**, ទាំង **ចំណូលមូលធនក្នុងប្រទេស** និង **ចំណូលមូលធនក្រៅប្រទេស** ។ ដូច្នេះ, ដើម្បីបានចំណេញពេលវេលាខ្លះ, ខ្ញុំបាទសូមមិនធ្វើការអធិប្បាយបន្ថែមទៀតទេ ។

### ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

#### ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

ក-១- <u>អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ</u>

ថវិកាថ្នាក់ជាតិឆ្នាំ ២០២៣ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ **ចំណាយចរន្ត** ឱ្យស្ថិតក្នុងកម្រិត ប្រមាណ **២០,៨ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៥,១ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **១៥,៨៧% នៃ ផសស**, **គឺមានកំណើន ៩,០%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ដែលក្នុងនោះ ៖

ក.១.១-<u>ចំណាយលើបន្ទុកបុគ្គលិក</u> ត្រូវបានគ្រោងប្រមាណ **៩,៦ ទ្រីលានរៀល**, មានសមាមាត្រស្មើនឹង **៤៥,៩% នៃ ចំណាយចរន្តថវិកាថ្នាក់ជាតិ**, ត្រូវជា **៧,២៨% នៃ ផសស**, **មានកំណើន ១០,៤%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ។ **ចំណាយបន្ទុកបុគ្គលិក** ត្រូវបានគ្រោងសម្រាប់៖

(១)-ការជ្រើសរើសក្របខ័ណ្ឌថ្មី ជំនួសអ្នកចូលនិវត្តន៍ក្នុងឆ្នាំ ២០២២ និង ការជ្រើសរើសក្របខ័ណ្ឌគ្រូបង្រៀន ចំនួន ៣ ០០០ កន្លែង បន្ទាប់ពីអាក់ខានចំនួន ២ ឆ្នាំ កន្លងមក; និង

(២)-ការអនុវត្តឡើងវិញនូវការដំឡើងបៀវត្សជូនមន្ត្រីរាជការ បន្ទាប់ពីបានផ្អាកនៅឆ្នាំ ២០២១ និង ឆ្នាំ ២០២២ ដោយសារវិបត្តិជំងឺកូវីដ-១៩ ។

ជាលទ្ធផល, នៅឆ្នាំ ២០២៣ បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការទូទៅ ត្រូវបានដំឡើងដល់ **១ ៣០០ ០០០** រៀល និង សម្រាប់គ្រូបង្រៀន និង គ្រូពេទ្យ ត្រូវបានដំឡើងដល់ **១ ៤០០ ០០០** រៀល ដូចមានជម្រាបជូនលម្អិតនៅក្នុងសេចក្តីថ្លែងហេតុ ។

ចំពោះ **ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា** នឹងត្រូវបានដំឡើងពី ៦៧ ម៉ឺនរៀល ទៅដល់ **៧១ ម៉ឺនរៀល** ចាប់ពីខែ មករា ឆ្នាំ ២០២៣ ផងដែរ ។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលនឹងដំឡើងប្រាក់សោធន និង កាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និង ថ្មី តាមរយៈវិធានការនៃការធ្វើសមាហរណកម្មប្រាក់សោធនតាមប្រព័ន្ធបៀវត្សចាស់ ចូលទៅក្នុងប្រព័ន្ធបៀវត្សថ្មី ឱ្យបានចប់ក្នុងរយៈពេល ២ ឆ្នាំ គឺក្នុងឆ្នាំ ២០២៣ និង ឆ្នាំ ២០២៤ ។ ថវិកាចំនួន **១៨១ ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់ការដំឡើងប្រាក់សោធន និង ការកាត់បន្ថយគម្លាតនេះ ។ ដូចនេះ, នៅឆ្នាំ ២០២៣, **ប្រាក់សោធនអប្បបរមាប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន,** រួមបញ្ចូលនូវ អតីតយោធិន និង អតីតមន្ត្រីនគរបាលជាតិ, **នឹងត្រូវបានដំឡើងពី ៦៩ ម៉ឺនរៀល នៅឆ្នាំ ២០២២ ទៅដល់ ៧៧ ម៉ឺនរៀល នៅឆ្នាំ ២០២៣ ដោយចាប់អនុវត្តពីខែ មករា ឆ្នាំ ២០២៣** ។

បន្ថែមលើនេះ, ក្នុងគោលបំណងបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការមិនយកពន្ធលើប្រាក់បៀវត្សកម្រិតអប្បបរមា និង ក្នុងស្មារតីជួយសម្រាលបន្ទុកជីវភាពមួយកម្រិតថែមទៀត ជូនដល់មន្ត្រីរាជការគ្រប់ប្រភេទ ព្រមទាំងកម្មករ-និយោជិត ក្នុងការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និង ការអនុវត្តប្រាក់ឈ្នួលអប្បបរមាជូនដល់កម្មករ-និយោជិត នៅឆ្នាំ ២០២៣, **រាជរដ្ឋាភិបាលបានសម្រេចដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សមិនជាប់ពន្ធ ពី ១ លាន ៣ សែនរៀល ទៅដល់ ១ លាន ៥ សែនរៀល ដោយចាប់អនុវត្តពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៣ តទៅ** តាមរយៈការដាក់ចេញនូវអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០២២ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និង តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ។

**ក.១.២-<u>ចំណាយក្រៅបន្ទុកបុគ្គលិក</u>** ត្រូវបានគ្រោងចំនួនប្រមាណ **១១,៣ ទ្រីលានរៀល,** មានសមាមាត្រស្មើនឹង **៥៤,១% នៃ ចំណាយចរន្តថវិកាថ្នាក់ជាតិ,** ត្រូវជា **៨,៦០% នៃ ផសស,**

គឺមានកំណើន **៧,៩%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ។ **ការគ្រោងកើនឡើងនេះ គឺសម្រាប់អនុវត្តអាទិភាពចម្បងសំខាន់ៗ រួមមាន៖ ការបន្តគ្រប់គ្រងឱ្យបាននូវការរីករាលដាលនៃជំងឺកូវីដ-១៩; ការបន្តកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និង ប្រព័ន្ធសុខាភិបាល ប្រកបដោយគុណភាព និង មានភាពឆ្លើយតបខ្ពស់, ការទ្រទ្រង់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ, ការបន្តស្តារ និង ជំរុញកំណើនសេដ្ឋកិច្ច ឱ្យស្ទុះងើបឡើងវិញ, ការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** នីតិកាល **ទី ៧ និង ការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ និង អាស៊ានប៉ារ៉ាហ្គេម ឆ្នាំ ២០២៣ ព្រមទាំងអាទិភាពមួយចំនួនទៀត** ដូចមានជម្រាបជូនលម្អិតនៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុ ។

### ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

**ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោងប្រមាណ **១៥,៨ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៣,៩ ប៊ីលានដុល្លារអាមេរិក**, **មានកំណើន ១៧,១%** ធៀបនឹងច្បាប់ឆ្នាំ ២០២២, មានសមាមាត្រស្មើនឹង **៤៣,១% នៃ ចំណាយថវិកាថ្នាក់ជាតិសរុប**, ត្រូវជា **១២,០១% នៃ ផសស**, ដែលក្នុងនោះ ៖

(១)- **គម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ ត្រូវបានគ្រោង** ក្នុងទំហំប្រមាណ **៥,៨៩% នៃ ផសស**, **មានការកើនឡើង ២៥,២%** ធៀបនឹងច្បាប់ឆ្នាំ ២០២២ ។

(២)- **គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** មានកំណើន **៦,២%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២, ត្រូវជា **៤,៧០% នៃ ផសស** ដែលស្មើនឹងប្រមាណ **១៥,៧% នៃ ចំណាយថវិការដ្ឋសរុប** ឆ្នាំ ២០២៣ ។

ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់បន្ថែមថា **ថវិកាចំណាយមូលធនថ្នាក់ជាតិ** ឆ្នាំ ២០២៣ ក៏បានឆ្លើយតបផងដែរទៅនឹងរបៀបវារៈអាទិភាព, កម្មវិធី និង គម្រោងសំខាន់ៗ របស់រាជរដ្ឋាភិបាលមួយចំនួនទៀត ជាពិសេសគឺ **ការបន្តអន្តរាគមន៍របស់រដ្ឋក្នុងការទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និង ពីសម្ពាធអតិផរណា ដែលជាបញ្ហាប្រឈមថ្មីបច្ចុប្បន្ន** ។

### គ- អំពីការកំណត់ពិតាននៃការខ្ចី

សម្រាប់ឆ្នាំ ២០២៣, រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចី ដូចតទៅ៖

(ទី១)-**គ្រោងធ្វើការបោះផ្សាយមូលបត្ររដ្ឋចំនួន** ៨១៣ **ប៊ីលានរៀល សមមូលនឹងប្រមាណ ២០០ លានដុល្លារអាមេរិក** សម្រាប់សងប្រាក់ដើមនៃការបោះផ្សាយមូលបត្រឆ្នាំ ២០២២ ចំនួន **២០០ ប៊ីលានរៀល**, សមមូលស្មើនឹងប្រមាណ **៤៩ លានដុល្លារអាមេរិក**, និង គ្រោងថវិកាចំនួន **៦១៣ ប៊ីលានរៀល**, សមមូលស្មើនឹងប្រមាណ **១៥១ លានដុល្លារអាមេរិក**

ទៀត, សម្រាប់ធ្វើហិរញ្ញប្បទានលើគម្រោងវិនិយោគដែលអាចផ្តល់ចំណូលដោយត្រង់មករាជរដ្ឋាភិបាល និង ផ្តល់ផលរហ័ស ដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគ និង ចីរភាពនៃការគ្រប់គ្រងបំណុល និង ថវិកាជាតិ ។ និង

( ទី២ )-**កំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍ ក្នុងកម្រិត ១ ៧00 លាន SDR ។**

ខ្ញុំសូមគូសបញ្ជាក់ថា, ជារួម, **ការបោះផ្សាយលក់មូលប័ត្ររដ្ឋ និង ទំហំនៃការខ្ចីនេះនឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ពោលគឺ, ជាទិដ្ឋភាពបច្ចេកទេស, ស្ថានភាពបំណុលសាធារណៈកម្ពុជា នៅតែត្រូវបានវាយតម្លៃថា មាន "ចីរភាព" និង "ហានិភ័យកម្រិតទាប" ដដែល ដោយរាល់សូចនាករគន្លឹះៗនៃការគ្រប់គ្រងបំណុលរបស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ។**

## VI. អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មានឱនភាពថវិកាចំនួនប្រមាណ **១,៥ ទ្រីលានរៀល** ដែលត្រូវបានគ្រោងឧបត្ថម្ភធនបំពេញតុល្យភាពដោយថវិកាថ្នាក់ជាតិ សម្រាប់បែងចែកជូនទៅថ្នាក់រដ្ឋបាលនីមួយៗ ។ ការឧបត្ថម្ភនេះ **មានកំណើន ១៥,៥%** ធៀបនឹងច្បាប់ឆ្នាំ ២០២២, ត្រូវជា **១,១១% នៃ ផសស** ។ ដូចគ្នានឹងថ្នាក់ជាតិដែរ, ប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ និង ក្រុមប្រឹក្សា-ឃុំ-សង្កាត់ ក្នុងឆ្នាំ ២០២៣ នេះ នឹងត្រូវបានដំឡើង ដូចមានជម្រាបជូនលម្អិតនៅក្នុងសេចក្តីថ្លែងហេតុ ។

## VII. បញ្ហាប្រឈម និង វិធានការក្នុងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០២៣

ការអនុវត្តក្របខ័ណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួន, ទាំងផ្នែកចំណូល, ទាំងផ្នែកចំណាយ, ដូចបានរៀបរាប់លម្អិតនៅក្នុងអត្ថបទសេចក្តីថ្លែងហេតុជូនដល់សមាជិក សមាជិកា នៃរដ្ឋសភារួចហើយ ដែលខ្ញុំសូមការអនុញ្ញាតមិនអធិប្បាយក្នុងពេលនេះទេ ។

## VIII. និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលស្នើធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកា បន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដើម្បីគោលដៅដូចខាងក្រោម ៖

**ទី១**-ផ្តល់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន **៥០២,៤ ប៊ីលានរៀល** ដែលក្នុងនោះ សម្រាប់គាំទ្រការបន្តអនុវត្តកម្មវិធីជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ និង ងាយរងគ្រោះ ចំនួន **៣៧៩,៤ ប៊ីលានរៀល** និង សម្រាប់ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ (គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ដែលងាយរងផលប៉ះទង្គិចពីសម្ពាធអតិផរណា ចំនួន **១២៣ ប៊ីលានរៀល** ។

**ទី២**-ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ-សង្កាត់ ចំនួន **២៣៨,៨ ប៊ីលានរៀល** ដើម្បីប្រើប្រាស់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ។

## IX. សេចក្តីសន្និដ្ឋាន

សរុបមក, ថវិកាឆ្នាំ ២០២៣ អាចត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដែលនឹងជួយឱ្យរាជរដ្ឋាភិបាលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈម និង ហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, សំដៅបន្តការពារអាយុជីវិត, លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន, ព្រមទាំងស្តារ និង ជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា តាមកន្លងប្រក្រតីភាពថ្មី; ហើយអាចប្រសិទ្ធនាមបានថា ជា **«ថវិកាវិត្ថារកម្មចំគោលដៅ ដោយផ្តល់អាទិភាពទី ១ ដល់ "មនុស្ស", ពិសេស ផ្តោតលើសុខភាព, ជីវភាព, និង សមធម៌, ព្រមជាមួយនឹងអាទិភាពនៃការបន្តជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច ស្របតាម "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣" ក៏ដូចជាកិច្ចប្រឹងប្រែងសម្រេចឱ្យបានជាអតិបរមានូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ក្នុងកម្មវិធីនយោបាយ, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ »** ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ, **សូម ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ប្រធានស្តីទីនៃរដ្ឋសភា** និង **អង្គរដ្ឋសភាទាំងមូល** មេត្តាពិនិត្យ និង ផ្តល់ការអនុម័តលើ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣** ដោយអនុគ្រោះ ។

សូមអរគុណ!